01327778

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**D296/4**

**អង្គបុរេជំនុំជម្រះ**
Pre-Trial Chamber
Chambre Préliminaire

***តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ***

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ៣២)**

**ចំពោះមុខ៖** **ចៅក្រម ប្រាក់ គឹមសាន** **ប្រធាន**
**ចៅក្រម Olivier BEAUVALLET**
**ចៅក្រម ន៉ី ថុល**
**ចៅក្រម Kang Jin BAIK**
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ៖ **ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៦**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 15 / 09 / 2016
ម៉ោង (Time/Heure) : 14 : 05
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ:**

**សេចក្តីសម្រេចទៅលើសំណើរបស់ អ៊ឹម ចែម ស្នើសុំការបញ្ជាក់ពីវិសាលភាពនៃសំណើសុំធ្វើអោយភាពរបស់លោក អោ អាន ទាក់ទងនឹងកំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់ដែលមិនបានថតសំឡេង**

**<u>សហព្រះរាជអាជ្ញា:</u>**
ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីការពារក្តី អ៊ឹម ចែម:</u>**
ប៊ិត ស៊ាងលីម
Wayne JORDASH

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី:</u>**
ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់

01327779



ស៊ិន សុវ៉ន

ទី ស្រ៊ីនណា

វ៉ែន ពៅ

Linda BEHNKE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំការបញ្ជាក់ពីវិសាលភាពនៃសំណើសុំធ្វើមោឃភាពរបស់លោក អោ អាន ទាក់ទងនឹងកំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់ដែលមិនបានថតសំឡេង”[1] (“សំណើ”) ដែលសហមេធាវីការពារក្តី អ៊ឹម ចែម បានដាក់នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦ (“សហមេធាវី” និង “អ្នកដាក់ពាក្យសុំ”)។

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ អោ អាន បានដាក់ពាក្យសុំធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់ដែលមិនមានខ្សែអាត់សំឡេង (“ពាក្យសុំរបស់ អោ អាន”)[2]។

2. នៅថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតបានសម្រេចបំបែកអ្នកដាក់ពាក្យសុំចេញពីសំណុំរឿង ០០៤ និងបង្កើតសំណុំរឿងថ្មីមួយលេខ ០០៤/១ (“ដីកាសម្រេចបំបែកសំណុំរឿង”)[3]។ សហចៅក្រមស៊ើបអង្កេតក៏បានណែនាំឱ្យសហមេធាវីក្នុងសំណុំរឿង ០០៤/១ ដាក់សំណើសុំបំពេញកិច្ចស៊ើបសួរក្នុងរយៈពេល ១៥ ថ្ងៃ ប្រសិនបើដាក់[4]។

3. នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជូនពាក្យសុំរបស់ អោ អាន ជូនទៅអង្គបុរេជំនុំជម្រះ[5]។

---

[1] សំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំការបញ្ជាក់ពីវិសាលភាពនៃសំណើសុំធ្វើមោឃភាពរបស់លោក អោ អាន ទាក់ទងនឹងកំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់ដែលមិនបានថតសំឡេង ដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦ ជាភាសាខ្មែរនៅថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៦ បានជូនដំណឹងជាភាសាទាំងពីរនៅថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ D296/2។

[2] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (“សំណុំរឿង ០០៤”) សំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលមិនមានខ្សែអាត់សំឡេង ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D296។

[3] សំណុំរឿង ០០៤ ដីកាសម្រេចបំបែកសំណុំរឿង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤ ចុះថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ D286/7 (“ដីកាសម្រេចបំបែកសំណុំរឿង”)។

[4] ដីកាសម្រេចបំបែកសំណុំរឿង កថាខណ្ឌ ៩។

[5] សំណុំរឿង ០០៤ ដីកាសម្រេចលើសំណើរបស់ អោ អាន សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលមិនបានថតសំឡេង ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ D296/1។

4. សហមេធាវីបានដាក់សំណើជាភាសាអង់គ្លេសនៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦ និងជាភាសាខ្មែរ នៅថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៦ បន្ទាប់មកបានដាក់សេចក្តីកែតម្រូវមួយ[6]។ ភាគីពុំបានដាក់ចម្លើយតបឡើយនៅក្នុងពេលកំណត់សម្រាប់ការដាក់នេះទេ។

## II. ភាពអាចទទួលយកបាន

5. តាំងពីដំបូង អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហមេធាវីពុំបានធ្វើសេចក្តីសន្និដ្ឋានណាមួយស្តីអំពីភាពទទួលយកបាននៃសំណើ និងពុំបានផ្តល់មូលដ្ឋានគតិយុត្តិចំពោះករណីនេះទេ។

6. អង្គបុរេជំនុំជម្រះរម្លឹកថា អ្នកដាក់ពាក្យសុំលែងជាភាគីក្នុងសំណុំរឿង ០០៤ ទៀតហើយ។ បញ្ហាដែលបានលើកឡើងនៅក្នុងសំណើ ដែលធ្វើឡើងនៅក្នុងក្របខណ្ឌនៃសំណុំរឿង ០០៤/១ ពិតជាបញ្ហាពិតប្រាកដ ដោយសារវាអាចពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចនៅក្នុងសំណុំរឿង ០០៤ បន្ទាប់ពីមានសំណើសុំធ្វើមោឃភាពភស្តុតាងដែលដូចគ្នាបេះបិទនៅក្នុងសំណុំរឿងទាំងពីរ។ ទោះជាយ៉ាងណាក្តី ស្ថានភាពនៅទីនេះគឺថា អ្នកដាក់ពាក្យសុំពុំមានសិទ្ធិក្នុងការធ្វើសំណើនៅក្នុងសំណុំរឿង ០០៤ ទេ បន្ទាប់ពីមានដីកាសម្រេចបំបែកសំណុំរឿងនៅថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ នោះ។

7. អង្គបុរេជំនុំជម្រះក៏រម្លឹកផងដែរថា អនុលោមតាមវិធាន ៧៤ និង ៧៦ នៃវិធានផ្ទៃក្នុង ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ ឬ ដាក់ពាក្យសុំទៅអង្គបុរេជំនុំជម្រះបាន តែក្នុងករណីដែលពាក់ព័ន្ធនឹងការមិនគោរពវិធានបញ្ញត្តប៉ុណ្ណោះ។ សំណើ*ដោយឡែក* *(sui generis)* ដែលសហមេធាវីបានដាក់ពុំមែនជាបណ្តឹងឧទ្ធរណ៍ ឬ ជាពាក្យសុំធ្វើមោឃភាពទេ តែផ្ទុយទៅវិញ សំណើនេះមានគោលបំណងបញ្ជាក់អំពីភស្តុតាងដែលប្រមូលបាននៅក្នុងសំណុំរឿងទេ។ នៅក្នុងកាលៈទេសៈទាំងនេះពុំមាននីតិវិធីក្នុងការធ្វើការអន្តរាគមន៍ឡើយ។

8. អង្គបុរេជំនុំជម្រះពិចារណាបន្ថែមថា ការស៊ើបអង្កេតចំពោះអ្នកដាក់ពាក្យសុំត្រូវបានបញ្ចប់តាំងពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ មកម្ល៉េះ[7] ហើយ ពាក្យសុំរបស់ អោ អាន ត្រូវបានដាក់តាំងពីថ្ងៃទី ៥

---

[6] *សេចក្តីកែតម្រូវ* លើសំណើរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំការបញ្ជាក់ពីវិសាលភាពនៃសំណើសុំធ្វើមោឃភាពរបស់លោក អោ អាន ទាក់ទងនឹងកំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់ដែលមិនបានថតសំឡេង ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ D296/3។

[7] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អ៊ឹម ចែម ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ D285។ *សេចក្តីសម្រេចទៅលើសំណើរបស់ អ៊ឹម ចែម ស្នើសុំការបញ្ជាក់ពីវិសាលភាពនៃសំណើសុំធ្វើមោឃភាពរបស់លោក អោ អាន ទាក់ទងនឹងកំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់ដែលមិនបានថតសំឡេង*

PRE-TRIAL CHAMBER E.C.C.C.

ខែ កុម្ភៈ ឆ្នាំ ២០១៦ មកម្ល៉េះ។ វិធាន ៦៦(១) នៃវិធានផ្ទៃក្នុងផ្តល់រយៈពេល ១៥ ថ្ងៃសម្រាប់ស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ ក្រោយពេលការស៊ើបអង្កេតបានបញ្ចប់ ដែលត្រូវបានពន្យារពេល ១៥ ថ្ងៃបន្ថែមទៀត បន្ទាប់ពីការចេញដីកាសម្រេចបំបែកសំណុំរឿងនៅថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៦។ ហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំនេះពុំបានដាក់ទាន់ពេលវេលាទេ។

9. ចុងក្រោយ អង្គបុរេជំនុំជម្រះសង្កេតឃើញថា សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/១ ត្រូវបានបំបែកចេញពីគ្នា ហើយសំណុំរឿងទាំងពីរនេះមានវិធីសាស្ត្រផ្សេងៗគ្នា។ ទោះបីសេចក្តីសម្រេចពាក់ព័ន្ធនឹងពាក្យសុំរបស់ អោ អាន នៅក្នុងសំណុំរឿង ០០៤ នឹងត្រូវចេញក៏ដោយ ក៏សេចក្តីសម្រេចនេះមានឥទ្ធិពលតែទៅលើសំណុំរឿងនេះប៉ុណ្ណោះ។

## III. ផ្នែកសម្រេចសេចក្តី

**ផ្អែកលើសំអាងហេតុទាំងនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ**

**បដិសេធ** មិនទទួលយកសំណើសំណើនេះ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៦**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គីមសាន** **Olivier BEAUVALLET** **នុំយ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**

*សេចក្តីសម្រេចទៅលើសំណើរបស់ អ៊ឹម ចែម ស្នើសុំការបញ្ជាក់ពីវិសាលភាពនៃសំណើសុំធ្វើមោឃភាពរបស់លោក អោ អាន ទាក់ទងនឹងកំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់ដែលមិនបានថតសំឡេង*